

# ធំពេក តូចពេក

Lavanya Karthik

Lavanya Karthik

letsreadasia.org



ម្ដាយប្រាប់ សានូថា៖ «សានូ ម៉ែ មិន
អាចពរកូនបានទេ។ កូនធំហើយ!»



ឪពុកប្រាប់ សាន្ធថា៖ «សាន្ធ កូនមិន
អាចដើរទៅសាលាតែម្នាក់ឯងបានទេ។
កូននៅតូចណាស់!»

តាប្រាប់ សានូថាៈ «សានូ ចៅមិនអាច
គេងនៅក្នុងអង្រឹងកូនង៉ែតបានទេ។
ចៅធំហើយ!»





យាយប្រាប់ សានូថា៖ « សានូ ចៅមិន
អាចពរប្អូនទៅសួនច្បារបានទេ។ ចៅ
នៅតូចណាស់!»



សានូ ឆ្ងល់ហេតុអ្វីក៏ធំពេក! តូចពេក!។
ហេតុអ្វីសានូ ធំពេក និង តូចពេកក្នុង
ពេលតែមួយយ៉ាងហ្នឹង?



សានូ ធំពេកមិនអាចស្លៀករ៉ូបពណ៌
ផ្កាឈូករបស់នាងពីមុនបានទេ។ នាង
នៅតូចពេកមិនអាចធ្វើនំដោយខ្លួនឯង
បានទេ។



តើសានូ ធំពេកមិនអាចជិះលើខ្នងតា
បានមែនទេ? តើ សានូ នៅតូចពេកមិន
អាចពរប្អូនបានមែនទេ?





សានូ សួរខ្លួនឯងថា៖ «តើខ្ញុំមានមាឌ
ប៉ុណ្ណាទើបសមល្មម?»





ម្ដាយញញឹម ហើយនិយាយថា« សានូ
កូនធំល្មមអាចចូលរៀនបានហើយ។»



ឪពុកនិយាយបន្ថែម៖ « ហើយកូននៅ
តូចល្មម ពុក អាចអៀវបាន។»



តានិយាយថា «ចៅធំល្មមអាចនាំតា
ដើរលេងពេលព្រឹកបាន។»



យាយនិយាយថា «ចៅនៅតូចល្មម
យាយអាចនិយាយរឿងនិទានឱ្យស្តាប់
បាន»។



អ្នកផ្ទះរបស់សានូ និយាយថា « សានូ
តូចល្មម ធំល្មម គឺសមល្មមតែម្តង!»
ទាំងអស់គ្នាឱបនាងយ៉ាងកក់ក្តៅ។

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
Too Big, Too Small, author: Lavanya Karthik. illustrator: by Lavanya Karthik. Published by Pratham Books, https://storyweaver.org.in/stories/16411-too-big-too-small © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Hor Pheahong and Prum Kunthearo